# របាយការណ៍
## ស្តីពី
## វិស័យកៅស៊ូប្រចាំឆ្នាំ២០១៣ និងទិសដៅការងារឆ្នាំ២០១៤

### ១. សេចក្តីផ្តើម

#### ក. ទស្សនៈទូទៅ

១. ដំណាំកៅស៊ូត្រូវបានដាំដុះជាលើកដំបូងក្នុងប្រវត្តិសាស្ត្រកម្ពុជា នាឆ្នាំ១៩១០ ដោយជនជាតិបារាំងឈ្មោះលោក **ប៊ូ យ៉ា** នៅក្នុងស្រុកព្រៃនប់ខេត្តកំពតលើផ្ទៃដីជាង១៥០ហិកតា។ ប៉ុន្តែការអភិវឌ្ឍដំណាំកៅស៊ូជាលក្ខណៈឧស្សាហកម្មដោយទ្រង់ទ្រាយធំត្រូវបានបង្កើតឡើងនាឆ្នាំ១៩២១ ដោយក្រុមហ៊ុនវិនិយោគរបស់បារាំងធំៗចំនួន៥នៅលើដីក្រហមបាសាល់នាខេត្តកំពង់ចាម ខេត្តក្រចេះ និងខេត្តរតនគិរីលើផ្ទៃដីទំហំជាង៥០.០០០ហិកតា។ រហូតមកដល់ឆ្នាំ១៩៦៩ ដំណាំកៅស៊ូនៅកម្ពុជាបានពង្រីកការដាំដុះលើផ្ទៃដីជាង៦៤.០០០ហិកតា ក្នុងនោះផ្ទៃដីចៀរជ័រជាង៣៩.០០០ហិកតា ដោយទទួលបានផលិតផលជ័រកៅស៊ូបានជាង ៥០.០០០តោន សម្រាប់ការប្រើប្រាស់នៅក្នុងស្រុកនិងការនាំចេញទៅបរទេស។ នៅជំនាន់នោះកម្ពុជាត្រូវបានអន្តរជាតិទទួលស្គាល់ច្បាស់ថា ជាប្រទេសដែលមានចម្ការកៅស៊ូ ល្អជាមួយនឹងទិន្នផលជ័រកៅស៊ូប្រកបដោយគុណភាពខ្ពស់ជាងគេនៅក្នុងតំបន់អាស៊ី។

២. ចាប់តាំងពីឆ្នាំ១៩៧០មកអាស្រ័យដោយសារសង្គ្រាមក្នុងស្រុក និងសង្គ្រាមឈ្លានពានរបស់បរទេស ជាពិសេសដំណាក់កាលចុងក្រោយស្ថិតក្រោមរបបគ្រប់គ្រងរបស់ពួកខ្មែរក្រហមរាល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តគ្រប់ផ្នែក រហូតដល់អាយុជីវិតប្រជាជនរាប់លាននាក់ត្រូវបានទទួលរងគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរស្ទើរដល់ឫសគល់។ ស្ថានភាពចម្ការកៅស៊ូ ក៏ដូចជាជីវិតកម្មកររាប់ពាន់នាក់ត្រូវទទួលរងគ្រោះថ្នាក់និងខូចខាតជាច្រើនកន្លែង។

៣. ចាប់ពីឆ្នាំ១៩៨០ រហូតមកដល់បច្ចុប្បន្នរដ្ឋាភិបាលបានរៀបចំដាក់ឲ្យដំណើរការស្តារនិងធ្វើអាជីវកម្មចម្ការកៅស៊ូចាស់ៗដែលនៅសេសសល់ឡើងវិញ និងបានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារនៅទូទាំងប្រទេសព្រមទាំង

បានផ្តល់ដីសម្បទានសេដ្ឋកិច្ចសម្រាប់ដំណាំកៅស៊ូដល់វិនិយោគិនក្នុងស្រុក និងបរទេសក្នុងគោលបំណងប្រែក្លាយកម្ពុជាទៅជាប្រទេសផលិតករកៅស៊ូ ដ៏មានសក្តានុពលនៅក្នុងតំបន់ និងជាប្រទេសផ្គត់ផ្គង់ផលិតផលកៅស៊ូមួយចំណែកចូលទៅក្នុងទីផ្សារពិភពលោក។

៤. គិតរហូតមកដល់ឆ្នាំ២០១៣ នេះផ្ទៃដីដាំដុះកៅស៊ូសរុបមានចំនួន៣២៨.៧៧១ហិកតាកើនឡើងចំនួន ១៧,៣% ធៀបនឹងឆ្នាំ២០១២ (២៨០.៣៥៥ហិកតា) ដែលរួមមាន៖ ផ្ទៃដីចម្ការកៅស៊ូកសិឧស្សាហកម្ម(អតីតចម្ការកៅស៊ូរដ្ឋ)មានចំនួន៥៥.៩០៨ហិកតា (ស្មើនឹង១៧,០០%) ផ្ទៃដីចម្ការកៅស៊ូដីសម្បទានសេដ្ឋកិច្ចមានចំនួន១៣៥.៤៤៦ហិកតា (ស្មើនឹង៤១,២០%) និងផ្ទៃដីចម្ការកៅស៊ូគ្រួសារតូចតាចនិងឯកជនមានចំនួន១៣៧.៤១៧ហិកតា (ស្មើនឹង៤១,៨០%) នៃផ្ទៃដីសរុប។ ផ្ទៃដីចៀរជ័រសរុបមានចំនួន៧៨.៤៩៣ហិកតាដែលមានផលិតផលចំនួន៨៥.២៤៤តោន។ តាមការព្យាករណ៍បណ្តោះអាសន្ន រហូតដល់ឆ្នាំ២០១៨កម្ពុជានឹងអាចមានផ្ទៃដីដាំដុះកៅស៊ូដល់ជាង៤២ម៉ឺនហិកតា និងទទួលបានផលិតផលជាង៤០ម៉ឺនតោនក្នុងមួយឆ្នាំ ហើយដល់ឆ្នាំ២០២០កម្ពុជានឹងអាចមានផ្ទៃដីដាំដុះកៅស៊ូដល់ជាង៤៥ម៉ឺនហិកតា និងទទួលបានផលិតផលជាង៤០-៤៥ម៉ឺនតោនក្នុងមួយឆ្នាំៗ។

## ខ. ទីផ្សារកៅស៊ូធម្មជាតិ

៥. ស្ថានភាពទីផ្សារកៅស៊ូអន្តរជាតិ គឺមានទំនាក់ទំនងដោយផ្ទាល់ដល់សេដ្ឋកិច្ចក្នុងតំបន់និងពិភពលោក។ បន្ទាប់ពីការធ្លាក់ចុះដោយមិនទៀងទាត់នៅក្នុងត្រីមាសទី១ ឆ្នាំ២០១៣ សេដ្ឋកិច្ចពិភពលោកបានរីកចម្រើនលូតលាស់ជាថ្មីម្តងទៀត។ បណ្តាប្រទេសនៅក្នុងតំបន់ចាយប្រាក់អឺរ៉ូ ក៏បានងើបចេញផុតពីវិបត្តិសេដ្ឋកិច្ចជាបន្តបន្ទាប់។ សហរដ្ឋអាមេរិកក៏បានទទួលជោគជ័យនៅក្នុងការពង្រីកសេដ្ឋកិច្ចរបស់ខ្លួនដល់កម្រិតសុវត្ថិភាពមួយ បើទោះបីជាមានការកែតម្រូវផ្នែកហិរញ្ញវត្ថុក៏ដោយ ហើយប្រទេសជប៉ុន ក៏បានទទួលផលពីកិច្ចខិតខំប្រឹងប្រែងជំរុញសេដ្ឋកិច្ចឡើងវិញយ៉ាងសំខាន់របស់ខ្លួន។ ទន្ទឹមនោះទោះបីជាកំណើននៅក្នុងសេដ្ឋកិច្ចនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍បានធ្លាក់ចុះក៏ដោយ ក៏សេដ្ឋកិច្ចរបស់ប្រទេសចិនត្រូវបានបង្កើនឡើងនៅពាក់កណ្តាលត្រីមាសទីពីរ ឆ្នាំ២០១៣ និងបានផ្តល់ជាកម្លាំងចលករជំរុញប្រាណយ៉ាងសំខាន់ដល់ទីផ្សារកៅស៊ូធម្មជាតិ។

៦. នៅលើផ្នែកនៃការផ្គត់ផ្គង់កៅស៊ូធម្មជាតិវិញ នៅក្នុងឆ្នាំ២០១៣កំណើនផលិតផលកៅស៊ូ គឺមានកម្រិតខ្ពស់ជាងការរំពឹងទុកពីដំបូងដោយស្ថិតក្នុងបរិមាណ១១,១៤៩លានតោន។ កំណើននេះត្រូវបានជួយទ្រទ្រង់ជាសំខាន់ពីប្រទេសថៃនិងវៀតណាមដែលបានបំពេញបន្ថែមផលិតផលក្នុងរង្វង់ ៤៧០.០០០តោនរវាងប្រទេសទាំងពីរជាមួយនឹងការកំណត់គោលដៅ ដើម្បីដើរឲ្យទាន់ប្រទេសម៉ាឡេស៊ីដែលជាប្រទេសផលិតករកៅស៊ូធម្មជាតិធំជាងគេទីបី ក្នុងពិភពលោក។ ការរួមចំណែកផ្សេងទៀតដល់វឌ្ឍនភាពនៃផលិតផលឆ្នាំ២០១៣ គឺចេញមកពីប្រទេសឥណ្ឌូណេស៊ី ចិន ហ្វីលីពីន និងកម្ពុជា ខណៈពេលនៃការបង្អាក់ផលិតផលនៅក្នុងប្រទេសម៉ាឡេស៊ី និងឥណ្ឌា រួមជាមួយនឹងការធ្លាក់ចុះនៅក្នុងប្រទេសស្រីលង្កាដែលបានបំពេញកំណើនបានខ្លះៗឡើងវិញ។

៧. ទំហំកៅស៊ូធម្មជាតិសរុបប្រចាំឆ្នាំ ដែលបាននាំចេញពីបណ្តាប្រទេសជាសមាជិករបស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ[1]ដែលហៅកាត់ថា ANRPC បានកើនឡើងដល់៦,៤%ក្នុងរយៈពេលពេញមួយឆ្នាំ គឺមានចំនួនដល់៨,៧២៣លានតោន។ ក្នុងពេលជាមួយគ្នានេះដែរទំហំសរុបនៃកៅស៊ូធម្មជាតិដែលបានប្រើប្រាស់ចំនួន៧,០១៦លានតោននៅក្នុងតំបន់ANRPC ក្នុងឆ្នាំ២០១៣គឺមានការកើនឡើងដល់៣៥០.១០០តោនបើធៀបទៅនឹងឆ្នាំមុន។

៨. ឆ្នាំ២០១៣ គឺជារយៈពេលនៃការពិនិត្យឡើងវិញអំពីសមិទ្ធផលនៃទីផ្សារកៅស៊ូធម្មជាតិនៅក្នុងរយៈពេលដប់ពីរខែនេះ។ បន្ទាប់ពីបានឡើងថ្លៃដល់៣,១០ដុល្លារក្នុងមួយគីឡូ នៅក្នុងត្រីមាសទីមួយ ឆ្នាំ២០១៣ កៅស៊ូប្រភេទTSR(Technically Specified Rubber)ដែលបានធ្វើការលក់ដូរដោយភាគច្រើននៅទីផ្សារគូឡាលំពួរនៃប្រទេសម៉ាឡេស៊ី និងទីផ្សារបាងកកនៃប្រទេសថៃបានធ្លាក់ចុះមកនៅក្នុងរង្វង់ ២,១៥ដុល្លារក្នុងមួយគីឡូ កាលពីខែកក្កដាមុននឹងតម្លៃត្រូវបានស្តារឡើងវិញក្នុងរយៈពេលពីរខែចុងក្រោយនេះ។ នៅក្នុងរយៈពេលនេះនិន្នាការនៃតម្លៃកៅស៊ូមានភាពអាក់អន្លួលច្រើនដែលបណ្តាលមកពីការបង្អាក់ដល់ការផ្គត់ផ្គង់ និងការកែតម្រូវសូចនាករម៉ាក្រូសេដ្ឋកិច្ច។ បន្ទាប់មកសន្និធិបានកើនឡើងខ្ពស់ដោយសារចំណាប់របស់អ្នកទិញបានថយចុះ ទិន្នន័យសេដ្ឋកិច្ចមានភាពច្របូកច្របល់និងសកម្ម-ភាពកេងរកផលប្រយោជន៍បានបន្តបង្កើនឲ្យមានចលនាឡើងចុះៗ នៃតម្លៃកៅស៊ូធម្មជាតិ។ថ្មីៗនេះតម្លៃកៅស៊ូគុណភាព TSR បានឈានមកដល់ចំណុចមួយទាបបំផុតបន្ទាប់មកនៅនឹងថ្កល់ក្នុងកម្រិតជាង២,២៥ដុល្លារក្នុងមួយគីឡូ។

## គ.សេណារីយោកៅស៊ូធម្មជាតិសម្រាប់ឆ្នាំ២០១៤

៩. សេណារីយោកៅស៊ូធម្មជាតិសម្រាប់ឆ្នាំ២០១៤ នៅតែមានស្ថានភាពទាបដដែល ក្នុងគ្រាដែលសេដ្ឋកិច្ចពិភពលោកបានធ្លាក់ចុះ។ មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) បាន ព្យាករណ៍ថាកំណើនសេដ្ឋកិច្ចពិភពលោកដែលមានជាមធ្យម២,៩% នៅក្នុងឆ្នាំ២០១៣ (គឺស្ថិតនៅក្រោមអត្រា៣,២% ដែលបានកត់ត្រាឃើញកាលពីឆ្នាំ២០១២) នឹងត្រូវកើនឡើងដល់៣,៦% នៅក្នុងឆ្នាំ២០១៤នេះ។ មួយផ្នែកធំនៃការស្តារ កំណើនឡើងវិញ ត្រូវបាននាំមុខដោយបណ្តាប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន។ កំណើននៅក្នុងទីផ្សារថ្មីៗ ទោះបីជាវឹងមាំក៏ដោយក៏រំពឹងថានឹងចុះខ្សោយជាងការព្យាករណ៍របស់ IMF កាលពីពេលមុនដែរ។

១០. អាស៊ីនិងអាហ្វ្រិក នឹងក្លាយទៅជាតំបន់ដែលមានឋាមភាពខ្លាំងជាងគេនៅក្នុងពិភពលោក។ ចំណែកប្រទេសនៅក្នុងទ្វីបអាស៊ីចិនគឺជាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនជឿនលឿនបំផុត។ ផលិតផលក្នុងស្រុកសរុប(GDP)របស់ចិននឹងកើនឡើងពី៧,៣% នៅក្នុងឆ្នាំ២០១៤ ដល់៧,៧% ជាមធ្យមប្រចាំឆ្នាំ នៅក្នុងចន្លោះឆ្នាំ ២០១៤-២០១៨។ ផលិតផលក្នុងស្រុកសរុបរបស់ឥណ្ឌាត្រូវបានរំពឹងថានឹងកើនឡើង៥,១% នៅឆ្នាំ២០១៤ និងជាមធ្យម៥,៩% នៅក្នុងចន្លោះឆ្នាំ២០១៤-២០១៨។ ចំណែកផលិតផលក្នុងស្រុកសរុបនៅទូទាំងពិភពលោកមិនបានកើនឡើងច្រើនទេ អាស្រ័យដោយសារភាពងាយរងគ្រោះក្នុងស្រុក នៅក្នុងសេដ្ឋកិច្ចនៃទីផ្សារកំពុងរីកចម្រើន ការធ្វើកំណែទម្រង់ផ្នែកហិរញ្ញវត្ថុដែលមិនទាន់បានបញ្ចប់ នៅក្នុងតំបន់ចាយប្រាក់អឺរ៉ូ សារពើពន្ធ និងហានិភ័យផ្នែកហិរញ្ញវត្ថុនៅក្នុងបណ្តាប្រទេសសេដ្ឋកិច្ចជឿនលឿនជាច្រើនផ្សេងទៀត រួមទាំងប្រទេសជប៉ុននិងសហរដ្ឋអាមេរិកផង។ រីឯហានិភ័យនៅក្នុងភូមិសាស្ត្រនយោបាយបានងើបឡើងវិញផងដែរ នៅក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ។

១១. នៅក្នុងលក្ខខណ្ឌនៃទស្សនវិស័យកៅស៊ូធម្មជាតិ បើយោងតាមអង្គភាពស៊ើបអង្កេតសេដ្ឋកិច្ច (Economist Intelligence Unit)បានឲ្យដឹងថាតម្រូវការនឹងកើនឡើងប្រចាំឆ្នាំត្រឹមកម្រិត៤% នៅឆ្នាំ២០១៤ និងឆ្នាំ២០១៥ បន្ទាប់ពីការធ្លាក់ចុះនៅក្នុងបណ្តាប្រទេសប្រើប្រាស់សំខាន់ៗមួយចំនួន ដែលបានធ្វើឲ្យអត្រាកំណើនថយចុះអស់១,៦%ក្នុងឆ្នាំនេះ។ តម្រូវការកៅស៊ូធម្មជាតិត្រូវបានរំពឹងថានឹងមានចំនួនសរុប ១១,៦លានតោន នៅក្នុងឆ្នាំ២០១៤និង១២,១លានតោននៅឆ្នាំ២០១៥។ ផលិតផលកៅស៊ូអាចនឹងមានការប្រែប្រួលតិចតួច នៅឆ្នាំនេះដោយសារតែតម្លៃចុះទាប

ហើយផលិតផលអាចកើនឡើងចំនួន៤,៦% គឺមានចំនួន១១,៨លានតោននៅឆ្នាំ ២០១៤ និង៤,៤% គឺមានចំនួន១២,៤លានតោននៅឆ្នាំ២០១៥។ អតិរេកពិភពលោក អាចកើនឡើងដល់ចំនួន១៣៤.០០០តោន នៅឆ្នាំ២០១៣ ចំនួន ២០០.០០០តោន នៅឆ្នាំ២០១៤ និងចំនួន២៥៧.០០០តោននៅឆ្នាំ២០១៥។ ការប្រើប្រាស់កៅស៊ូនៅក្នុងប្រទេសចិនអាចនឹងកើនឡើង២% នៅឆ្នាំ២០១៤ និងក្នុងរង្វង់៤%នៅឆ្នាំ២០១៥។ តម្រូវការកៅស៊ូរបស់ឥណ្ឌាអាចនឹងធ្លាក់ចុះប្រមាណ ៤%នៅឆ្នាំ២០១៣និងឡើងដល់៨,៥% នៅក្នុងឆ្នាំ២០១៤។ផលិតផលកៅស៊ូរបស់ថៃត្រូវបានរំពឹងថានឹងកើនឡើង៦% នៅឆ្នាំ២០១៤និង៥%នៅឆ្នាំ២០១៥។

## ២. ការងារសំខាន់ៗរបស់អគ្គនាយកដ្ឋានកៅស៊ូក្នុងឆ្នាំ២០១៣

អគ្គនាយកដ្ឋានកៅស៊ូបាននិងកំពុងអនុវត្តការងារចម្បងៗក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដូចមានខាងក្រោម :

### ក.រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានកៅស៊ូ

១២. អនុក្រឹត្យលេខ១៨៨ អនក្រ.បកចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា អគ្គនាយកដ្ឋានកៅស៊ូមានបេសកកម្មជានាការអភិវឌ្ឍនិងការគ្រប់គ្រងវិស័យកៅស៊ូគ្រប់ផ្នែកស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល សំដៅរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចគ្រួសារនិងសង្គម កាត់បន្ថយភាពក្រីក្រ លើកកំពស់គុណភាពផលិតផលកៅស៊ូ ដើម្បីជានាដល់ការប្រកួតប្រជែងនៅលើទីផ្សារតាមរយៈការផ្តល់សេវាស្រាវជ្រាវ និងការផ្ទេរបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាព ព្រមទាំងអភិវឌ្ឍនិងការគ្រប់គ្រងខ្សែចង្វាក់ផលិតកម្ម អាជីវកម្មកែច្នៃសំដៅជំរុញពាណិជ្ជកម្មផលិតផលកៅស៊ូ។

១៣. អគ្គនាយកដ្ឋានកៅស៊ូមានភារកិច្ចធ្វើជាសេនាធិការឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទលើការងារមានជាអាទិ៍ៈរៀបចំនិងអនុវត្តយុទ្ធសាស្ត្រគោលនយោ-បាយចក្ខុវិស័យ គោលដៅ បេសកកម្ម និងកម្មវិធីអភិវឌ្ឍវិស័យកៅស៊ូនៅកម្ពុជា សម្រាប់រយៈពេលមធ្យមនិងវែង កសាងមូលដ្ឋានគតិយុត្ត បទដ្ឋានច្បាប់ស្តីពីការគ្រប់គ្រងនិងអភិវឌ្ឍកៅស៊ូជានារាល់ដំណើរការផ្សេងៗទៀត ដែលមានការពាក់ព័ន្ធដល់វិស័យកៅស៊ូនៅទូទាំងប្រទេស ព្រមទាំងភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ឲ្យ។

១៤. អគ្គនាយកដ្ឋានកៅស៊ូ មាននាយកដ្ឋានជំនាញចំនួន៥ និងវិទ្យាស្ថានស្រាវជ្រាវ

កៅស៊ូមួយ ជាសេនាធិការក្នុងការបំពេញភារកិច្ចទទួលខុសត្រូវតាមជំនាញសំដៅជំរុញ ពង្រឹង តាមដាន ស្រាវជ្រាវ និងអភិវឌ្ឍវិស័យកៅស៊ូនៅទូទាំងប្រទេស។

១៥. អគ្គនាយកដ្ឋានកៅស៊ូមានមន្ត្រីរាជការសរុបចំនួន១៩១នាក់ ក្នុងនោះ ស្រីមានចំនួន៥៣នាក់ ដែលកំពុងបម្រើការងារនៅតាមនាយកដ្ឋាន និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូដូចមានខាងក្រោម៖

| | | |
|---|---|---|
| ១. | ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន | ៥នាក់ |
| ២. | នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម | ៣៩នាក់ |
| ៣. | នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ | ២៨នាក់ |
| ៤. | នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ | ២០នាក់ |
| ៥. | នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ | ១៥នាក់ |
| ៦. | នាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ | ២៣នាក់ |
| ៧. | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៦១នាក់ |
| | សរុប.......... | ១៩១នាក់ |

តារាងបែងចែកមន្ត្រីរាជការតាមកម្រិតជំនាញដូចមានក្នុងតារាងខាងក្រោម៖

| លរ | បរិយាយ | កម្រិតសញ្ញាបត្រ | | | | | |
|---|---|---|---|---|---|---|---|
| | | បណ្ឌិត | អនុបណ្ឌិត | បរិញ្ញាបត្រ | មធ្យម | គ្មាន | សរុប |
| ១ | ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន | - | ៣ | ១ | ១ | - | **៥** |
| ២ | នា.រដ្ឋបាល និងនីតកម្ម | ១ | ៤ | ៥ | ៣ | ២៦ | **៣៩** |
| ៣ | នា.អភិវឌ្ឍន៍កៅស៊ូ | ១ | ២ | ១៨ | ២ | ៥ | **២៨** |
| ៤ | នា.ផែនការ ហិរញ្ញវត្ថុ និងស្ថិតិ | - | ៤ | ៤ | ៥ | ៧ | **២០** |
| ៥ | នា.ទីផ្សារ និងសហ.អន្តរជាតិ | - | ៣ | ៧ | ៤ | ៩ | **២៣** |
| ៦ | នា.កែច្នៃផលិតផលកៅស៊ូ | - | ១ | ៧ | ៣ | ៤ | **១៥** |
| ៧ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ២ | ៦ | ២៨ | ១៤ | ១១ | **៦១** |
| | សរុប.... | **៤** | **២៣** | **៧០** | **៣២** | **៦២** | **១៩១** |

# រចនាសម្ព័ន្ធអគ្គនាយកដ្ឋានកៅស៊ូ

(យោងអនុក្រឹត្យលេខ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨)



## ខ. ការងារហិរញ្ញវត្ថុ

១៦. ចាប់ពីឆ្នាំ២០១០មកដល់ឆ្នាំ២០១៣ អគ្គនាយកដ្ឋានកៅស៊ូ បានទទួលថវិកាតាមកម្មវិធីដែលបាននិងកំពុងអនុវត្តក្នុងកម្មវិធីទី១ (អនុកម្មវិធីទី១១ ស្តីពី "ជម្រុញការវិនិយោគ និងអភិវឌ្ឍន៍ដំណាំកៅស៊ូប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ និងចីរភាព" មានទឹកប្រាក់ជាង៨១៨ លានរៀល និងកម្មវិធីទី៣ (អនុកម្មវិធីទី១ ស្តីពីលើកកម្ពស់ការពង្រឹងក្របខ័ណ្ឌច្បាប់ និងអភិបាលកិច្ច មានទឹកប្រាក់ជាង១៧២ លានរៀល) និងថវិកាមិនមែនកម្មវិធីចំនួន ៤.៥១៩លានរៀលផងដែរ។

**តារាងសរុបថវិកាមិនមែនកម្មវិធី និងតាមកម្មវិធី ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៣**

*ឯកតា: .000រៀល*

| ល.រ | ឆ្នាំ | ថវិកាមិនមែនកម្មវិធី | | ថវិកាតាមកម្មវិធីទី១ | | | ថវិកាតាមកម្មវិធីទី៣ | | |
|---|---|---|---|---|---|---|---|---|---|
| | | ឥណទានអនុម័ត | អនុវត្ត | ឥណទានអនុម័ត | អនុវត្ត | ភាគរយ | ឥណទានអនុម័ត | អនុវត្ត | ភាគរយ |
| ១ | ២០១០ | 277 000 | 1 257 096 | 131 300 | 130 860 | 99,6 | 89 700 | 44 699 | 49,8 |
| ២ | ២០១១ | 107 000 | 921 941 | 150 000 | 149 671 | 99,8 | 73 000 | 36 503 | 50,0 |
| ៣ | ២០១២ | 105 000 | 1 072 608 | 160 000 | 159 532 | 99,7 | 37 000 | 14 705 | 39,7 |
| ៤ | ២០១៣ | 110 000 | 1 266 843 | 390 000 | 378 433 | 97,0 | 106 000 | 76 677 | 72,3 |
| សរុប | | **599 000** | **4 518 490** | **831 300** | **818 496** | **98,5** | **305 700** | **172 585** | **56,5** |

*- ចំពោះថវិកាមិនមែនកម្មវិធីបានអនុម័តសម្រាប់តែជំពូក៦១+៦២*

## គ. ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ

១៧. ចាប់ពីឆ្នាំ២០១០មក អគ្គនាយកដ្ឋានកៅស៊ូបាននិងកំពុង អនុវត្តអនុកម្មវិធីទី១ នៃកម្មវិធីទី៣ ស្តីពីការពង្រឹងស្ថាប័នក្របខណ្ឌច្បាប់និងការអភិវឌ្ឍធនធានមនុស្ស ដោយបានអនុវត្តសកម្មភាពមួយ គឺការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ ក្នុងគោលបំណងជានាការគ្រប់គ្រង និងអភិវឌ្ឍដំណាំកៅស៊ូនៅទូទាំងប្រទេស សម្រាប់បម្រើផលប្រយោជន៍សេដ្ឋកិច្ចជាតិ សង្គម បរិស្ថាន និងជាពិសេសសម្រាប់គ្រប់តួអង្គដែលពាក់ព័ន្ធផ្នែកកៅស៊ូធម្មជាតិ។

១៨. រហូតមកដល់ចុងឆ្នាំ២០១៣នេះ សេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូនឹងត្រូវបញ្ចប់ដែលរួមមាន១២ជំពូក ៩៤មាត្រា ដោយក្រុមការងារតាក់តែងសេចក្តីព្រាងច្បាប់នេះបានប្រជុំពិភាក្សាចំនួន១៤៦ដង ប្រជុំអន្តរនាយកដ្ឋានអគ្គនាយកដ្ឋានកៅស៊ូចំនួន៧លើក និងកិច្ចប្រជុំជាមួយអ្នកពិគ្រោះយោបល់អន្តរជាតិក្រោមជំនួយ AFD ចំនួន៥ដងសិក្ខាសាលា១ដង បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់កម្រិតអន្តរនាយក-ដ្ឋានក្រសួងកសិកម្មនិងប្រតិបត្តិករកៅស៊ូចំនួន៣ដង និងបានឆ្លងការផ្តល់យោបល់ពីនាយកដ្ឋាននីតិកម្មកសិកម្ម ស្តីពីទម្រង់នៃសេចក្តីព្រាងច្បាប់នេះបានចំនួន១ដង។

១៩. ក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូកំពុងបង្កើនល្បឿន ក្នុងការប្រជុំកែសម្រួលពីលទ្ធផលសិក្ខាសាលាចុងក្រោយ ដើម្បីធ្វើឱ្យកាន់តែមានខ្លឹមសារនិងអត្ថន័យប្រសើរឡើង ដែលអាចទទួលយកបានពីគ្រប់ភាគី។សង្ឃឹមថា សេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ នឹងបានធ្វើការកែសម្រួលរួចរាល់នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៤ មុននឹងបញ្ជូនទៅក្រសួងកសិកម្មដើម្បីអនុវត្តតាមនីតិវិធីក្នុងការកសាងច្បាប់។

## ឃ. គម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា

២០. ផ្អែកតាមអនុសញ្ញាហិរញ្ញប្បទានគម្រោង "ធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា" N°CKH 1123 01H រវាងរាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ(AFD) ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី១២ខែកក្កដា ឆ្នាំ២០១២ និងលិខិតលេខ៤៤២២សហវ ចុះថ្ងៃទី០៤ខែកក្កដា ឆ្នាំ២០១២ ស្តីពីករណីសំណើសុំហិរញ្ញប្បទាន សម្រាប់ជួយទ្រទ្រង់ការអនុវត្តគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជាអគ្គនាយកដ្ឋានកៅស៊ូ បាននិងកំពុងអនុវត្តការងារគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូ ក្នុងគោលបំណងកែលម្អផលិតភាពដំណាំកៅស៊ូនៅកម្ពុជាដោយវត្ថុសម្ភារដែលមានការបញ្ជាក់ត្រឹមត្រូវ។ ការងារដែលត្រូវអនុវត្តក្នុងគម្រោងនេះរួមមាន (១)ការធ្វើបញ្ជីសារពើភ័ណ្ឌច្បារពូជកៅស៊ូនៅទូទាំងប្រទេស (២)ការបង្កើតច្បារពូជ និងថ្នាលកូនកៅស៊ូ សម្រាប់ជួសកូនកៅស៊ូក្នុងច្បារពូជណាដែលមិនត្រឹមត្រូវ (៣)ការធ្វើវិភាគDNAទៅលើច្បារពូជដែលមានស្រាប់ (៤)ការដាំជួសកូនកៅស៊ូពូជត្រឹមត្រូវក្នុងច្បារពូជនិង (៥)ការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃច្បារពូជត្រឹមត្រូវ។ គម្រោងនេះមានរយៈពេល៣ឆ្នាំ (២០១៣-២០១៥)ក្នុងទឹកប្រាក់ចំនួន២.៦៨៨.០០០អឺរ៉ូ(ជាង៣លានដុល្លារសហរដ្ឋ) ក្នុងនោះរួមមានថវិកា៖

- AFDមានចំនួន ១.០០០.០០០អឺរ៉ូ
- បដិភាគរាជរដ្ឋាភិបាល(MEF,DGH,IRCC)មានចំនួន ២៧៦.០០០អឺរ៉ូ

- ធនាគារអភិវឌ្ឍន៍ជនបទសម្រាប់ឲ្យខ្ចីចំនួន ១.០០១.០០០អឺរ៉ូ
- ចម្ការកៅស៊ូកសិឧស្សាហកម្មនិងដីសម្បទានសេដ្ឋកិច្ចចំនួន៤១១.០០០អឺរ៉ូ

២១. ក្រុមការងាររបស់គម្រោងបានចុះយកសំណាកស្លឹកកៅស៊ូនៅច្បារពូជ សរុបចំនួន ១.១២០សំណាក ដែលក្នុងនោះ៖ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា មានចំនួន ៦៦០សំណាកលើ៤១ក្លូន ច្បារពូជឯកជនចំនួន៣លើ៥ក្លូនសរុប៣០០សំណាក (២០សំណាក/ក្លូន/ម្ចាស់) និងនៅច្បារពូជចម្ការកៅស៊ូកសិឧស្សាហកម្មលើ៨ក្លូន មានចំនួន១៦០សំណាក(២០សំណាក/ក្លូន) ព្រមទាំងបានផ្ញើសំណាកទាំងនោះទៅCIRADប្រទេសបារាំងដើម្បីវិភាគDNA។ រីឯលទ្ធផលនៃការវិភាគ DNA នៃសំណាកក្លូនកៅស៊ូចំនួន១.១២០ កំពុងដំណើរការ។

## ខ. ការងារទិន្នន័យនិងស្ថិតិកៅស៊ូ

២២. នៅក្នុងឆ្នាំ២០១៣នេះ អគ្គនាយកដ្ឋានកៅស៊ូ បានបំពេញសកម្មភាពការងារតាមគម្រោងជាអាទិភាព ដោយមានកិច្ចសហការជាមួយមន្ទីរកសិកម្មខេត្តពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន បានចុះស្រង់ស្ថិតិកៅស៊ូគ្រួសារឯកជននៅក្នុងខេត្តចំនួន១៨ រួមមានៈ រតនគិរី ស្ទឹងត្រែង ក្រចេះ មណ្ឌលគិរី កំពង់ចាម កំពង់ធំ ព្រះវិហារ បាត់-ដំបង ប៉ៃលិន ពោធិ៍សាត់ បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ កោះកុង ព្រះ-សីហនុ កំពត ព្រៃវែង និងស្វាយរៀង។ ជារួមក្នុងរយៈពេល៤ឆ្នាំនេះ ក្រុមការងារអនុវត្តគម្រោងអាទិភាព បានចុះស្រង់ស្ថិតិកៅស៊ូគ្រួសារដែលមានផ្ទៃដីដាំដុះចំនួន ១៣៧.៤១៧ហ.ត ស្មើនឹងចំនួន២៨.១៧៨គ្រួសារ ។

២៣. ចម្ការកៅស៊ូនៅកម្ពុជាចែកចេញជា០២ផ្នែកសំខាន់គឺៈ ក្រុមហ៊ុនកៅស៊ូកសិឧស្សា-ហកម្មក្នុងនោះ (អតីតចម្ការកៅស៊ូរដ្ឋចំនួន១០ក្រុមហ៊ុនរួមទាំងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា មានផ្ទៃដី៥៥.៩០៨ហ.ត និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច"ELCs" ចំនួន៩៦ក្រុមហ៊ុនមានផ្ទៃដី១៣៥.៤៤៦ហ.ត) និងកៅស៊ូគ្រួសារ(Smallholdings) ស្ថិតនៅក្នុង១៨ខេត្តដែលមានផ្ទៃដីចំនួន១៣៧.៤១៧ហ.ត។

២៤. ក្នុងឆ្នាំ២០១២-២០១៣ ក៏បានចុះស្រង់ស្ថិតិរោងចក្រ-សិប្បកម្មកែច្នៃផលិតផលកៅស៊ូ ក្នុងស្រុកគោលដៅចំនួន១៨ ក្នុងខេត្តចំនួន៥ សរុបមានរោងចក្រ-សិប្បកម្មកែច្នៃផលិតផលកៅស៊ូចំនួន៧០កន្លែង ក្នុងនោះមានរោងចក្រកែច្នៃជ័រកៅស៊ូចំនួន ៣០កន្លែងសិប្បកម្មកែច្នៃជ័រកៅស៊ូសន្លឹកចំនួន៣៦កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូចំនួន០៤ កន្លែង។

## ច.ការងារផ្សព្វផ្សាយនិងបណ្តុះបណ្តាល

២៥. បានយកចិត្តទុកដាក់លើការងារផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូ ដោយបានចុះបើកវគ្គផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារនៅខេត្តចំនួន៩គឺៈ បាត់ដំបង ប៉ៃលិន ព្រះវិហារ កំពង់ធំ កំពង់ចាម ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី ដោយមានកសិករចូលរួមសរុប៥៨៦នាក់ ដើម្បីឱ្យកសិករអ្នកដាំកៅស៊ូ និងកសិករដែលមានបំណងដាំកៅស៊ូទទួលបានចំណេះដឹងនេះយកទៅអនុវត្តលើការជ្រើសរើសពូជការងារដាំដុះថែទាំព្យាបាលជម្ងឺ និងការបើកមុខចៀរដំបូងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដើម្បីឱ្យទទួលបានលទ្ធផលល្អនៅថ្ងៃខាងមុខ។

២៦. បានយកចិត្តទុកដាក់លើការងារផ្សព្វផ្សាយបច្ចេកទេសកែច្នៃជ័រកៅស៊ូ ដោយបានចុះបើកវគ្គផ្សព្វផ្សាយនិងបណ្តុះបណ្តាលដល់កសិករកៅស៊ូគ្រួសារបានចំនួន២វគ្គ។

២៧. បានយកចិត្តទុកដាក់លើការងារផ្សព្វផ្សាយពីទីផ្សារកៅស៊ូ ដោយបានចុះបើកវគ្គផ្សព្វផ្សាយ ដល់កសិករកៅស៊ូគ្រួសារ បានចំនួន ៦វគ្គ។

២៨. ដើម្បីបង្កើនសមត្ថភាពយល់ដឹងដល់កសិករកៅស៊ូគ្រួសារ ក្នុងការអនុវត្តការចៀរជ័របានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ធានាបានការប្រមូលផលយូរអង្វែង ប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ក្រុមការងារអនុវត្តគម្រោងបានចុះបើកវគ្គបង្រៀនពីការបើកមុខចៀរនិងបច្ចេកទេសចៀរជ័រ ដល់កសិករកៅស៊ូគ្រួសារ បានចំនួន២វគ្គដល់កសិករកៅស៊ូគ្រួសារនៅខេត្តប៉ៃលិន បាត់ដំបង និងព្រះវិហារ ដែលមានកសិករចូលរួមចំនួន១២៥នាក់។

២៩. បានបើកវគ្គបណ្តុះបណ្តាលមន្ត្រីបង្គោល ដើម្បីបង្កើនសមត្ថភាពយល់ដឹងដល់មន្ត្រីបង្គោលលើជំនាញដំណាំកៅស៊ូ និងប្រែក្លាយជាអ្នកផ្សព្វផ្សាយបន្តដល់អ្នកដាំកៅស៊ូជាពិសេសជួយដល់កសិករដាំកៅស៊ូ និងអ្នកមានបំណងដាំកៅស៊ូក្នុងខេត្តរបស់ខ្លួនបានចំនួន០១វគ្គនៅខេត្តបាត់ដំបង ដោយមានមន្ត្រីកសិកម្មខេត្តចូលរួមសរុបចំនួន ៤០នាក់។

## ឆ.ការងារស្រាវជ្រាវ និងពិសោធន៍

៣០. វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា មានភារកិច្ចដឹកនាំនិងសម្រេចរាល់សកម្មភាពស្រាវជ្រាវ និងពិសោធន៍សំដៅជំរុញការអភិវឌ្ឍលើគ្រប់ផ្នែកនៃដំណាំកៅស៊ូចូលរួមក្នុងសកម្មភាពជំរុញផ្នែកបច្ចេកទេសសុរុវឌ្ឍិកម្មគុណភាពនិងតម្លៃកៅស៊ូ។

៣១. ការងារដែលបាននិងកំពុងអនុវត្តលើការស្រាវជ្រាវ រួមមាន៖

(១) ការស្រាវជ្រាវអំពីការបង្កាត់ពូជនិងជម្រើសពូជកៅស៊ូ ហើយនិងផ្សព្វផ្សាយដោយបានបង្កើតប្រព័ន្ធ និងតាមដានទិន្នន័យចម្ការពិសោធន៍ពូជ និងជម្រើសពូជកៅស៊ូ ចំនួន ២១ចម្ការពិសោធន៍រួមមាន៖

-ស្ថានីយ៍អនុវត្តន៍របស់វិទ្យាស្ថានចំនួន១១ពិសោធន៍
-ចម្ការកៅស៊ូក្រុមហ៊ុនសុកក្តនីកាអ៊ិនវេសមេនគ្រុបចំនួន៤ពិសោធន៍
-ចម្ការកៅស៊ូក្រែក(ខេមបូឌា) ចំនួន ៥ ពិសោធន៍
-ចម្ការពិសោធន៍នៅក្នុងខេត្តមណ្ឌលគិរីចំនួន០១ពិសោធន៍
-រៀបចំអនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជាសម្រាប់ឆ្នាំ២០១៤-២០១៦

| Class I | Class II | Class III |
|---|---|---|
| IRCA 130 | GT 1 | BPM 24 |
| IRCA 230 | IRCA 109 | IRCA 111 |
| RRIM 600 | RRIC 121 | IRCA 41 |
| PB 280 | RRIM 712 | PR 303 |
| | PB 260 | PB 254 |
| | PB 217 | PB 310 |
| | RRIC 101 | PB 314 |
| | | PB 324 |
| | | PB 330 |
| | | PR 261 |
| | | KV 4 |
| | | PB 235 |
| | | RRIC 100 |

(២) ការស្រាវជ្រាវសរីរវិទ្យា-អាជីវកម្ម ដោយបានបង្កើតនិងតាមដានទិន្នន័យពិសោធន៍ចំនួន ១៦ពិសោធន៍ ក្នុងនោះរួមមានៈ

-ស្ថានីយ៍អនុវត្តន៍របស់វិទ្យាស្ថានចំនួន ០៨ពិសោធន៍
-ចម្ការកៅស៊ូក្រែក(ខេមបូឌា) ចំនួន ២ពិសោធន៍
-បង្កើតចំការពិសោធន៍ថ្មីចំនួន០៦ពិសោធន៍

(៣) ការស្រាវជ្រាវការដាំដុះ៖ និងការពារដោយបានបង្កើតនិងតាមដានទិន្នន័យចម្ការពិសោធន៍ចំនួន១៩ នៅក្នុងស្ថានីយ៍អនុវត្តន៍វិទ្យាស្ថាន ដែលបានបង្កើតឡើងតាំងពីឆ្នាំ២០០៥ រហូតមកដល់បច្ចុប្បន្ននិងបង្កើតចម្ការសមុច្ច័យដំណាំគ្របដីចំនួន៣០ប្រភេទ។ ចូលរួមតម្លើងឧបករណ៍ស្រាវជ្រាវបន្ថែម (Throw fall and Stem flow)

និងសម្របសម្រួលបេសកកម្មស្រាវជ្រាវរបស់សាកលវិទ្យាល័យNagoya, Kyushu and Hawaiiនៅស្ថានីយ៍អនុវត្តន៍ចំនួន០៩លើក។

(៤)ការបណ្តុះបណ្តាលនិងផ្សព្វផ្សាយៈ វិទ្យាស្ថាន បានធ្វើការបណ្តុះបណ្តាលដល់កសិករដាំកៅស៊ូចំនួន០៩ប្រធានបទៈ

| ល.រ | វគ្គបណ្តុះបណ្តាល | អ្នកចូលរួម |
|---|---|---|
| ១ | ការបណ្តុះបណ្តាលស្តីពីការដាំដុះនិងថែទាំកៅស៊ូ | ៣៧ |
| ២ | ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសត្វចង្រៃនិងជម្ងឺ | ៦៨ |
| ៣ | ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងច្បារពូជនិងថ្នាលបណ្តុះកូន | ៣៨ |
| ៤ | ការបណ្តុះបណ្តាលស្តីពីបច្ចេកទេសប្រមូលទឹកជ័រ (ចៀរជ័រ-២វគ្គ) | ២០៣ |
| ៥ | ការបណ្តុះបណ្តាលស្តីពីការកែច្នៃកៅស៊ូសន្លឹកនិងការធ្វើចំណាត់ថ្នាក់ | ២៩ |
| ៦ | ការបណ្តុះបណ្តាលស្តីពីការកែច្នៃកៅស៊ូដុំ | ១៦ |
| ៧ | ការបណ្តុះបណ្តាលអំពីការគ្រប់គ្រងជីជាតិដី (២លើក) | ៣០ |
| ៨ | ការបណ្តុះបណ្តាលអំពីការវិភាគជម្ងឺ | ១០ |
| ៩ | អនុសាសន៍ក្លូនកៅស៊ូឆ្នាំ២០១១-២០១៣ និង ២០១៤-២០១៦ | ៥១ |
| | សរុប (១២០% នៃផែនការ) | ៤៨២ |

ក្រៅពីនោះវិទ្យាស្ថានដឹកនាំកម្មសិក្សាដល់និស្សិតតាមសាកលវិទ្យាល័យនិងបណ្តាបុគ្គលិកក្រុមហ៊ុនចម្ការកៅស៊ូមួយចំនួនដូចខាងក្រោមៈ

- បានដឹកនាំនិស្សិតសរសេរសារណាបានចំនួន១២នាក់
- បានទទួលបុគ្គលិកមន្ទីរពិសោធន៍ក្រុមហ៊ុនក្រែកធ្វើកម្មសិក្សាចំនួន០៧នាក់
- បានទទួលនិស្សិតនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញធ្វើកម្មសិក្សាចំនួន០៦នាក់
- បានទទួលសាស្ត្រាចារ្យ និងនិស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្មធ្វើទស្សនកិច្ចសិក្សាចំនួន០៣លើកដែលមានអ្នកចូលរួមប្រមាណ១៥០នាក់
- បានទទួលភ្ញៀវអន្តរជាតិធ្វើទស្សនកិច្ចចំនួន៤លើក និងមានអ្នកចូលរួមប្រមាណ២០រូប ក្នុងនោះមានគណៈប្រតិភូនៃ MRB, AFD និងស្ថានទូតបារាំងហើយនិងអ្នកវិនិយោគដំណាំកៅស៊ូជនជាតិម៉ាឡេស៊ីនិងឥណ្ឌា។

## ៥. ការងារមន្ទីរពិសោធន៍យថាប្រភេទជ័រកៅស៊ូ

៣២. ការងារដែលបាននិងកំពុងអនុវត្តផ្នែកមន្ទីពិសោធន៍ រួមមានៈ

(១) ការធ្វើតេស្តវិភាគសំណាកយថាប្រភេទចំនួន៣១២សំណាក ដើម្បីបញ្ជាក់គុណ-

ភាពកៅស៊ូ និងការកែច្នៃរបស់រោងចក្រនីមួយៗ។

(២) បានចុះបញ្ជិការមន្ទីរពិសោធន៍យថាប្រភេទនៅក្រុមហ៊ុនស៊ីហ្វវីសសស់ (ខេមបូឌា) លីមីធីត ដើម្បីបានលិខិតទទួលស្គាល់ជាផ្លូវការនិងសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា។

(៣) បានទទួលយកបុគ្គលិកមន្ទីរពិសោធន៍យថាប្រភេទក្រុមហ៊ុនក្រែក(ខេមបូឌា)ខូអិលធីឌីចំនួន៧រូប ដើម្បីធ្វើការបណ្តុះបណ្តាលអំពីរបៀបធ្វើតេស្ត និងចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ។

(៤) បានចូលរួមវគ្គបណ្តុះបណ្តាល "e-precision" និងកិច្ចប្រជុំស្តីពីផលិតផលជ័រកៅស៊ូឬផលិតផលចេញពីជ័រកៅស៊ូ នៅប្រទេសមីយ៉ាន់ម៉ា។

(៥) ក្រុមការងារអាស៊ាន ផ្នែកផលិតផលចេញពីជ័រកៅស៊ូបានលើកគម្រោងស្នើសុំជំនួយបច្ចេកទេសទៅប្រទេសអូស្ត្រាលី នូវែលហ្សេឡង់ ដើម្បីជួយទទួលស្គាល់ដល់អ្នកផ្តល់កម្មវិធីសមត្ថភាពតេស្តវិភាគ (PT) ស្របតាមបមាណីយ៍ISO/IEC17043 សម្រាប់វិស័យកៅស៊ូរបស់បណ្តាប្រទេសអាស៊ាន។

(៦) ការរៀបចំសេចក្តីព្រាង ស្តីពីការបង្កើតមន្ទីរពិសោធន៍អាស៊ាន សម្រាប់ផលិតផលកៅស៊ូធម្មជាតិ នៅក្នុងបណ្តាប្រទេសអាស៊ាន ដែលត្រូវមានការទទួលស្គាល់តាមបមាណីយ៍ ISO/IEC17025 និងការចូលរួមកម្មវិធីសមត្ថភាពតេស្តវិភាគ (PT) ស្របតាមISO/IEC17043:2010។

(៧) ការចូលរួម និងសរុបលទ្ធផលធ្វើតេស្តវិភាគអន្តរមន្ទីរពិសោធន៍លើកទី ១០៧, ១០៨ និង១០៩ ជាមួយសមាគមកៅស៊ូអន្តរជាតិដើម្បីពង្រឹងសមត្ថភាពតេស្តវិភាគ និងសម្រាប់កិច្ចសន្យាកៅស៊ូបញ្ជាក់គុណភាពតាមបច្ចេកទេស(TSR: Technically Specified Rubber)។

(៨) ត្រួតពិនិត្យតាមដានរោងចក្រកែច្នៃកៅស៊ូ (CSR: Cambodian Specified Rubber) នៅក្រុមហ៊ុនចម្ការកៅស៊ូស៊ីហ្វ៉ាប់បើរ លីមីធីត ខេត្តរតនគិរីនិងក្រុមហ៊ុនចម្ការកៅស៊ូស៊ីហ្វវីសសស់ (ខេមបូឌា)លីមីធីតខេត្តក្រចេះ និងបានប្រកាសទទួលស្គាល់មន្ទីរពិសោធន៍មូលដ្ឋានក្រុមហ៊ុនជាផ្លូវការ។

(៩) ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីស្តង់ដារនិងគុណភាពកៅស៊ូនៅក្រុមប្រឹក្សាកៅស៊ូម៉ាឡេស៊ី (MRB: Malaysian Rubber Board)និងបានបង្ហាញអំពីការគ្រប់គ្រងនិងត្រួតពិនិត្យឧស្សាហកម្មកៅស៊ូប្រទេសម៉ាឡេស៊ី និងទំនាក់ទំនងស្តង់ដារអន្តរជាតិលើការធ្វើតេស្តវិភាគនិងវិញ្ញាបនបត្រផលិតផលកៅស៊ូ។

## ឈ. ការងារសហប្រតិបត្តិការអន្តរជាតិ

### • សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ

៣៣. សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC: Association of Natural Rubber Producing Countries)គឺជាអង្គការអន្តររដ្ឋាភិបាលដែលបានបង្កើតឡើងកាលពីឆ្នាំ១៩៧០។ សមាជិកភាពរបស់សមាគមត្រូវបានបើកទូលាយចំពោះរដ្ឋាភិបាលនៃបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ។ គិតរហូតមកដល់ឆ្នាំ២០១៣ សមាគមនេះមានរដ្ឋាភិបាលជាសមាជិកចំនួន១១ប្រទេសរួមមាន៖កម្ពុជា ចិន ឥណ្ឌា ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ប៉ាពួញូហ្គីណេ ហ្វីលីពីន សឹង្ហបុរី ស្រីលង្កា ថៃ និងវៀតណាម។ បរិមាណផលិតផលកៅស៊ូធម្មជាតិរបស់ប្រទេសទាំង១១ គឺមាន៩២%នៃផលិតផលកៅស៊ូធម្មជាតិក្នុងពិភពលោក។ ***ទស្សនៈវិស័យ*** របស់សមាគមគឺធ្វើឲ្យឧស្សាហកម្មកៅស៊ូធម្មជាតិ មានចីរភាពប្រកបដោយលក្ខណៈសេដ្ឋកិច្ចសង្គម និងបរិស្ថាន។ ***បេសកកម្ម*** គឺកែលម្អជាបន្តបន្ទាប់នូវផលិតភាពនៃកៅស៊ូគ្រួសារ កាត់បន្ថយចំណាយបង្កើនតម្លៃបន្ថែម ផ្នែកលំហូរខាងក្រោម រកប្រភពប្រាក់ចំណូលបន្ថែម ប្រើប្រាស់លទ្ធភាព និងបទពិសោធន៍កៅស៊ូធម្មជាតិសម្រាប់ជួយបរិស្ថាននិងបង្កើនសុខុមាលភាពរបស់កសិករកៅស៊ូ។

៣៤. គោលបំណងរបស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ត្រូវបានអនុវត្តនិងផ្តល់ផលប្រយោជន៍ទៅវិញទៅមកដល់គ្រប់ប្រទេសជាសមាជិកគឺ៖

- នាំមកនូវការសម្របសម្រួលក្នុងផលិតកម្មនិងទីផ្សារកៅស៊ូធម្មជាតិ
- លើកកម្ពស់កិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងចំណោមប្រទេសជាសមាជិក
- នាំមកនូវប្រាក់កម្រៃខ្ពស់និងតម្លៃមានស្ថេរភាពសម្រាប់កៅស៊ូធម្មជាតិ។

៣៥. កម្ពុជាបានចូលជាសមាជិកពេញសិទ្ធិ របស់សមាគមនៃបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ(Association of Natural Rubber Producing Countries "ANRPC") កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩។ ការចូលជាសមាជិករបស់កម្ពុជានៅក្នុងសមាគមនេះ គឺជាការធ្វើសមាហរណ៍កម្មវិស័យកៅស៊ូធម្មជាតិកម្ពុជាទៅក្នុងពិភព-លោកដែលមានប្រទេសចំនួន១១ចូលរួមជាសមាជិក និងមានប្រទេសមួយចំនួនកំពុងសិក្សាលទ្ធភាពដើម្បីចូលរួមក្នុងសមាគមនេះផងដែរ។ សមាជិកភាពនេះបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់ឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា ដូចជាការទទួលបាននូវព័ត៌មាន ស្ថិតិ បទពិសោធន៍ បច្ចេកវិទ្យាវិទ្យាសាស្ត្រថ្មីៗនិន្នាការនៃការផ្គត់ផ្គង់ តម្រូវការ ថ្លៃលក់ និងសិក្សាអំពីការប្រែប្រួលអាកាសធាតុពីបណ្តា

ប្រទេសជាសមាជិក និងពីស្ថាប័នពាក់ព័ន្ធនានា ជាពិសេសគឺទទួលបានការបណ្តុះបណ្តាលពីDemand-Supply Modelingក្នុងការរៀបចំស្ថិតិនិន្នាការផ្គត់ផ្គង់និងតម្រូវការកៅស៊ូធម្មជាតិក្នុងរយៈពេលជាក់លាក់ណាមួយនាពេលអនាគត និងការបណ្តុះបណ្តាលផ្សេងៗទៀត ដែលជាការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យកៅស៊ូ។

៣៦. សកម្មភាពរបស់អគ្គនាយកដ្ឋានកៅស៊ូនៅក្នុងសមាគម នៅក្នុងឆ្នាំ២០១៣កន្លងមកគឺៈ (១)បានចូលរួមវគ្គបណ្តុះបណ្តាលនៅប្រទេសថៃ រយៈពេលបីថ្ងៃស្តីពីការរៀបចំគម្រូស្ថិតិផ្គត់ផ្គង់និងតម្រូវការកៅស៊ូធម្មជាតិ(Supply-Demand Statistics Modeling) (២)បានចូលរួមក្នុងកិច្ចប្រជុំក្រុមជំនាញរបស់Expert Group on Promotion of NR as Environment Friendly Raw Material ស្តីពី "Eligibility of Rubber Cultivation for Carbon Credit under CDM" នៅគូឡាលំពួរ ប្រទេសម៉ាឡេស៊ី រយៈពេលពីរថ្ងៃ និង(៣)បានចូលរួមក្នុងកិច្ចប្រជុំ និងសន្និសីទកៅស៊ូឆ្នាំរបស់សមាគមនៃបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិនៅទីក្រុង Colombo នៃប្រទេសស្រីលង្កា ដែលបានប្រព្រឹត្តទៅអស់រយៈពេល៦ថ្ងៃ គឺចាប់ពីថ្ងៃទី៧-១៤ ខែតុលា ឆ្នាំ២០១៣រួមមានសន្និសីទកៅស៊ូអន្តរជាតិប្រចាំឆ្នាំ២០១៣ កិច្ចប្រជុំគណៈកម្មាធិការបញ្ហាឧស្សាហកម្ម,គណៈកម្មាធិការព័ត៌មាននិងស្ថិតិ និងកិច្ចប្រជុំនិងសន្និបាតគណៈកម្មាធិការប្រតិបត្តិរបស់សមាគម។

៣៧. កិច្ចប្រជុំឆ្នាំ២០១៣នេះបានដាក់ចេញនូវការងារចំពោះមុខមួយចំនួន រួមមាន (១) ការចុះសិក្សាអង្កេតស្រាវជ្រាវអំពីប្រវត្តិនៃចម្ការកៅស៊ូគ្រួសារ (Profile of Small holding)និង(២)ការបំពេញតារាងប្រវត្តិឧស្សាហកម្មកៅស៊ូ(Rubber Industry Profiling)និងផ្ញើជូនអគ្គលេខាធិការដ្ឋានសម្រាប់កិច្ចប្រជុំលើកក្រោយ។

ជាមួយគ្នានោះ ក៏បានលើកឡើងអំពីកម្មវិធីសម្រាប់កិច្ចប្រជុំឆ្នាំ២០១៤ និងឆ្នាំបន្តផងដែរ។ សម្រាប់ឆ្នាំ២០១៤ខាងមុខប្រទេសជាសមាជិកត្រូវបញ្ជូនមន្ត្រីជំនាញចូលរួមប្រជុំតាមកាលបរិច្ឆេទដូចខាងក្រោមៈ

| ល.រ | ព្រឹត្តិការណ៍ | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|
| ១ | Joint - ANRPC - IRRDB - ISRG Workshop on Climate Change | ពាក់កណ្ដាលខែកក្កដា ឆ្នាំ២០១៤ | អគ្គលេខាធិការដ្ឋាន ANRPC ទីក្រុងគូឡាលំពួរ ម៉ាឡេស៊ី |
| ២ | Workshop on Supply-Demand Modeling | ពាក់កណ្ដាលខែកក្កដា ឆ្នាំ២០១៤ | អគ្គលេខាធិការដ្ឋាន ANRPC ទីក្រុងគូឡាលំពួរ ម៉ាឡេស៊ី |
| ៣ | Annual Conference and Related Meeting Of ANRPC, 2014 | ពាក់កណ្ដាលខែតុលា ឆ្នាំ២០១៤ | ទីក្រុង គូឡាលំពួរ ម៉ាឡេស៊ី |

៣៨. នៅឆ្នាំ២០១៤នេះ ប្រទេសម៉ាឡេស៊ីត្រូវទទួលវេនធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំសន្និសីទ និងសន្និបាតប្រចាំឆ្នាំ២០១៤។ **សម្រាប់ឆ្នាំ២០១៥ប្រទេសកម្ពុជានឹងត្រូវធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំទាំងនេះ**។ប្រទេសប៉ាពួញូហ្គីណេ ក៏បានសន្យាទទួលធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំក្នុងឆ្នាំ២០១៦ ផងដែរ។

### • ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ

៣៩. ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB: International Rubber Research and Development Board) គឺជាបណ្ដាញស្រាវជ្រាវនិងអភិវឌ្ឍន៍ ដែលប្រមូលផ្ដុំរាល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូធម្មជាតិស្ទើរតែគ្រប់ប្រទេសផលិតកៅស៊ូធម្មជាតិទាំងអស់ដែលមាន៩៥% នៃបរិមាណផលិតផលកៅស៊ូធម្មជាតិនៅក្នុងពិភពលោក។ បទពិសោធន៍របស់វិទ្យាស្ថានទាំងនេះគឺថាសមាជិកភាពរបស់IRRDB បានបញ្ចូលនូវសារៈសំខាន់ថ្មីៗដ៏មានតម្លៃនោះគឺ៖

- អាចឲ្យពួកគេប្រមូលផ្ដុំកម្លាំងលើមូលដ្ឋានបត់បែននិងមិនរឹងរ៉ា
- ចែករំលែកនូវបទពិសោធន៍និងបញ្ហាទាំងឡាយរបស់ពួកគេ
- ចៀសវាងធ្វើការជាន់គ្នាដោយឥតប្រយោជន៍បញ្ចូលធនធានហិរញ្ញវត្ថុរបស់ខ្លួនដែលយល់ថាសមស្របដើម្បីអនុវត្តសកម្មភាពដែលមានទំហំធំពេកឬថ្លៃពេកសម្រាប់វិទ្យាស្ថានមួយ។

៤០. ដើមកំណើតរបស់ IRRDB គឺបានកើតឡើងតាំងពីឆ្នាំ១៩៣៤។ គណៈកម្មាធិការបទបញ្ជាកៅស៊ូអន្តរជាតិត្រូវបានបង្កើតឡើង ដើម្បីការពារផលិតករកៅស៊ូធម្មជាតិពីផលប៉ះពាល់នៃតម្លៃទាបបំផុតកាលពីពាក់កណ្ដាលឆ្នាំ១៩៣០ ដោយព្យាយាម

ធ្វើការគ្រប់គ្រងផលិតផល និងការនាំចេញដើម្បីកែសម្រួលការផ្គត់ផ្គង់ឲ្យត្រូវគ្នានឹងតម្រូវការ។ គណៈកម្មាធិការក៏ទទួលស្គាល់ផងដែរនូវសារៈសំខាន់នៃការលើកទឹកចិត្តដល់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ដែលមានគោលដៅត្រឹមត្រូវ។ នៅឆ្នាំ១៩៣៧ បានបង្កើតក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ ដើម្បីសម្របសម្រួលការងារនៃវិទ្យាស្ថានជាតិ និងគណៈកម្មាធិការអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ ដើម្បីទទួលយកការអភិវឌ្ឍពាណិជ្ជកម្មនៃលទ្ធផលស្រាវជ្រាវ។ នៅក្នុងឆ្នាំ១៩៦០អង្គការទាំងពីរនេះបានរំលាយចូលគ្នា ដើម្បីក្លាយជាក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិវិញ ដែលសព្វថ្ងៃមានភារកិច្ចគ្របដណ្តប់លើរាល់ទិដ្ឋភាព នៃកៅស៊ូធម្មជាតិចាប់តាំងពីការដាំដុះរហូតដល់ការអភិវឌ្ឍផលិតផលថ្មីៗ។

៤១. វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានចូលជាសមាជិកទី១៦នៃក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ ក្នុងសម័យប្រជុំប្រចាំឆ្នាំរបស់ខ្លួនកាលពីថ្ងៃទី២៧-២៨ខែកញ្ញាឆ្នាំ២០០១នៅទីក្រុង Montpellier នៃសាធារណរដ្ឋបារាំង។ចាប់តាំងពីពេលនោះមកថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូនិងមន្ត្រីជំនាញរបស់វិទ្យា-ស្ថាន តែងបានចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំនិងសកម្មភាពផ្សេងៗទៀត របស់ IRRDB រួមមាន៖

- ការផ្លាស់ប្តូរគំនិត រវាងបុគ្គលិករបស់វិទ្យាស្ថាននៃប្រទេសជាសមាជិកក្នុងឱកាសនៃកិច្ចប្រជុំដែលបានរៀបចំឡើងដោយIRRDB
- សកម្មភាពដែលបានស្នើឡើងដោយក្រុមជំនាញរបស់IRRDB
- ការបណ្តុះបណ្តាលនិងគម្រោងការសំខាន់ៗ ដែលបានស្នើឡើងដោយវិទ្យាស្ថានមួយឬច្រើននៃប្រទេសជាសមាជិក ដោយធ្វើការរួមគ្នានៅក្នុងករណីមួយចំនួនជាមួយហិរញ្ញវត្ថុពីខាងក្រៅដែលគម្រោងទាំងនេះបង្កើតបានជា "កម្មវិធីស្រាវជ្រាវអន្តរជាតិ"របស់IRRDB ។

៤២ IRRDB បង្កើតក្រុមឯកទេសដែលរាល់សកម្មភាពត្រូវបានដឹកនាំដោយអ្នកសម្របសម្រួលតាមផ្នែករួមមាន៖

- ការកែលម្អ
- រោគសាស្ត្រ
- សរីរសាស្ត្រនិងអាជីវកម្ម
- បច្ចេកវិទ្យានិងការប្រើប្រាស់ចុងក្រោយ
- ទិដ្ឋភាពសង្គម-សេដ្ឋកិច្ចនិង

- ក្សេត្រវិទ្យា។

៤៣. នៅឆ្នាំ២០១៣ កិច្ចប្រជុំប្រចាំឆ្នាំនិងសន្និសីទកៅស៊ូអន្តរជាតិ បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៤-២៩ខែមិថុនាឆ្នាំ២០១៣នៅសណ្ឋាគារMillenium Hotel Mayfair នៃទីក្រុងឡុងដ៍ប្រទេសអង់គ្លេស។ កម្មវិធីនៃកិច្ចប្រជុំគឺមានដូចតទៅ៖

- ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ កិច្ចប្រជុំរបស់គណៈកម្មាធិការនាយកគណៈ-កម្មាធិការប្រតិបត្តិនិងមន្ត្រីទំនាក់ទំនងរបស់IRRDB នៅសាលប្រជុំនៃមជ្ឈមណ្ឌលស្រាវជ្រាវកៅស៊ូTun Abdul Razak។
- ថ្ងៃទី២៧ខែមិថុនាឆ្នាំ២០១៣កិច្ចប្រជុំរបស់ក្រុមប្រឹក្សារបស់ IRRDB នៅសណ្ឋាគារ Millenium Hotel ។

- **កិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ**

៤៤. ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍដែលហៅកាត់ថា AFD (Agence Française de Développement) គឺជាគ្រឹះស្ថានសាធារណៈនៃកិច្ចសហប្រតិបត្តិការ បានអនុវត្តការងារអស់រយៈពេលជាង៧០ឆ្នាំមកហើយ ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រនិងជំរុញការអភិវឌ្ឍនៅក្នុងបណ្តាប្រទេសភាគខាងត្បូងនិងឯនាយសមុទ្រ។ តាមរយៈការជួយឧបត្ថម្ភប្រាក់កម្ចីមូលនិធិ ជានាឬកិច្ចសន្យាកាត់បន្ថយបន្ទុកបំណុល និងការអភិវឌ្ឍAFD បានផ្តល់ហិរញ្ញប្បទានគម្រោងកម្មវិធីនិងការសិក្សានិងគាំទ្រដៃគូរបស់ខ្លួននៅក្នុងការពង្រឹងសមត្ថភាពរបស់ខ្លួន។

៤៥. AFD បានទទួលការអនុញ្ញាតឲ្យចូលធ្វើអន្តរាគមន៍នៅកម្ពុជានាឆ្នាំ១៩៩៣។ ការបើកទីភ្នាក់ងាររបស់ខ្លួននៅទីក្រុងភ្នំពេញគឺនៅខែកញ្ញានាឆ្នាំដដែល។ ជាប្រវត្តិ-សាស្ត្រ AFD បានប្រមូលផ្តុំសកម្មភាពជួយឧបត្ថម្ភរបស់ខ្លួនទៅលើផ្នែកកសិកម្មការអភិវឌ្ឍជនបទនិងសុខាភិបាល។ ចាប់តាំងពីខែកក្កដា ឆ្នាំ២០០៩ មធ្យោបាយអន្តរាគមន៍របស់ AFD នៅកម្ពុជាមានការវិវត្តគួរឲ្យកត់សម្គាល់។ ដើម្បីជួយទ្រទ្រង់ដល់កំណើនរបស់ប្រទេស AFD ដោយមានការព្រមព្រៀងជាមួយអាជ្ញាធរកម្ពុជាផងបានតម្រង់ទិសទៅលើការជួយទ្រទ្រង់ដល់ផ្នែកផលិតកម្ម តាមរយៈការផ្តល់ប្រាក់កម្ចីមិនធានាពីរដ្ឋ មានន័យថាប្រាក់កម្ចីដោយផ្ទាល់ដល់សហគ្រាសឬធនាគារឯកជនឬរដ្ឋដែលមិនបានទទួលការធានាពីរាជរដ្ឋាភិបាលកម្ពុជា។

៤៦. ដោយឡែកនៅលើផ្នែកកៅស៊ូធម្មជាតិក្នុងឆ្នាំ២០១៣កន្លងមក AFD បានផ្តល់

ហិរញ្ញប្បទានលើគម្រោងបីគឺ៖

- គម្រោងធម្មនិយាមកម្មប្បារពូជកៅស៊ូដែលមានទឹកប្រាក់ជាង១លានដុល្លារ
- គម្រោងផ្តល់អ្នកពិគ្រោះយោបល់អន្តរជាតិ លើសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូដែលមានទឹកប្រាក់ជាង១០០.០០០ដុល្លារសហរដ្ឋ។
- គម្រោងអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារ ដែលមានការយល់ព្រមពីរាជរដ្ឋាភិបាលរួចហើយ។ ក្នុងដំហានដំបូងគម្រោងនេះត្រូវធ្វើការសិក្សាជាពីរដំណាក់កាលគឺការសិក្សាអំពីបញ្ហាដីធ្លី និងការសិក្សាអំពីកិច្ចដំណើរការ នៃគម្រោងទាំងមូលក្នុងឆ្នាំ២០១៤នេះ។

**● កិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យអន្តរជាតិ**

៤៧. បានចូលរួមសហការ ជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Nagoya នៃប្រទេសជប៉ុនក្នុងការថែទាំនិងជួសជុលឧបករណ៍ Sap flow, $CO_2$ profile និងបានចូលរួមសហការការងារជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Kuyshu ដើម្បីស្រាវជ្រាវអំពី leaf photosynthesis និងបានចូលរួមសហការការងារជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Hawaii សហរដ្ឋអាមេរិកដើម្បីថែទាំនិងជួសជុលឧបករណ៍ Flux Tower។

**● កិច្ចសហប្រតិបត្តិការជាមួយក្រសួងកសិកម្មនៃសាធារណរដ្ឋប្រជាមានិតចិន**

៤៨. ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជានិងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូចិន បានព្រមព្រៀងចុះអនុស្សរណៈនៃការយោគយល់គ្នាកាលថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ នៅទីក្រុងកូឡំបូ ប្រទេសស្រីលង្កា។

៤៩. បច្ចុប្បន្ន តាមរយៈកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយរវាងកម្ពុជា-ចិន និងតាមកិច្ចប្រជុំលើកទី២ កាលពីថ្ងៃទី៩-១០ ខែឧសភាឆ្នាំ២០១៣ របស់ក្រុមការងារទ្វេភាគីកម្ពុជា-ចិន សម្រាប់កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម នៅសណ្ឋាគារសុខា ខេត្តព្រះសីហនុ ភាគីចិនបានយល់ព្រមពិភាក្សាលម្អិត និងឈានទៅចុះហត្ថលេខាលើអនុស្សរណៈយោគយល់(MoU) ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យឧស្សាហកម្មកៅស៊ូធម្មជាតិ។ អគ្គនាយកដ្ឋានកៅស៊ូ បានរៀបចំសេចក្តីព្រាងអនុស្សរណៈមួយបានដាក់ជូនភាគីចិនរួចហើយ តែមិនទាន់ទទួលបានធ្វើការចុះហត្ថលេខាជាផ្លូវការនៅឡើយទេ។

៥០. ជាមួយគ្នានោះដែរ អគ្គនាយកដ្ឋានកៅស៊ូ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ក៏បានលើកជាសំណើជូនភាគីចិន ក្នុងការជួយគាំទ្រនូវគម្រោងមួយចំនួនរួមមាន ការបង្កើតការិយាល័យកៅស៊ូនៅតាមខេត្ត, ការគ្រប់គ្រងចម្ការកៅស៊ូគ្រួសារតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (Geographical Information System- GIS) និងការបង្កើនគុណភាពកៅស៊ូធម្មជាតិកម្ពុជាតាមរយៈការពង្រឹងបរិក្ខាសម្រាប់ធ្វើតេស្ត និងការស្រាវជ្រាវ (Improving the Quality of Cambodian Natural Rubber through Enhancing Rubber Testing Facilities and Researches)។

## ៣. បញ្ហាប្រឈម

៥១. ជាមួយនឹងការអនុវត្តខាងលើអគ្គនាយកដ្ឋានកៅស៊ូបានជួបនូវបញ្ហាប្រឈម និងការលំបាកមួយចំនួនមានដូចខាងក្រោម ៖

- ការខ្វះខាតថវិកា សម្ភារ និងមធ្យោបាយ(រថយន្ត) សម្រាប់ដំណើរការការងារ និងការចុះបំពេញបេសកកម្មនៅតាមបណ្តាខេត្តដែលមានចម្ការកៅស៊ូនៅទូទាំងប្រទេស
- ការលំបាកទំនាក់ទំនងជាមួយម្ចាស់ឬតំណាងចម្ការកៅស៊ូ រោងចក្រ-សិប្បកម្មមួយចំនួនដែលមិនបានសហការក្នុងការចុះពិនិត្យនិងស្រង់ទិន្នន័យ និងមានការលាក់លៀមក្នុងការផ្តល់ព័ត៌មានដែលទាក់ទងនឹងវត្ថុធាតុដើម និងបរិមាណផលិតផល។ ម្យ៉ាងទៀត ទីតាំងចម្ការកៅស៊ូគ្រួសារ ស្ថិតនៅរាយប៉ាយឆ្ងាយៗ ពិបាកផ្លូវចូលទៅដល់ និងពិបាករកជួបម្ចាស់ចម្ការផ្ទាល់ក្នុងការចុះស្រង់និងសាកសួរព័ត៌មានពាក់ពន្ធ័ការងារដាំដុះកៅស៊ូ។ល។
- ការខ្វះខាតធនធានមនុស្ស មន្ត្រីភាគច្រើនមានភាពអសកម្មក្នុងការងារ មន្ត្រីមួយចំនួនមិនមានសមត្ថភាពគ្រប់គ្រាន់ និងខ្វះឆន្ទៈ ក្នុងការបំពេញភារកិច្ចដែលបានប្រគល់ឲ្យ និងជាពិសេសមិនមានការិយាល័យកៅស៊ូនៅតាមខេត្តដែលបានជះឥទ្ធិពលដល់ការងារចរន្តប្រចាំថ្ងៃរបស់អគ្គនាយកដ្ឋាន។
- ក្រុមហ៊ុនវិនិយោគកៅស៊ូលើដីសម្បទានសេដ្ឋកិច្ចភាគច្រើន មិនបានសហការល្អជាមួយអគ្គនាយកដ្ឋានកៅស៊ូ ក្នុងការផ្តល់ព័ត៌មាន និងស្ថិតិផ្ទៃដីដាំដុះកៅស៊ូតាមឆ្នាំ តាមពូជដែលបានប្រើប្រាស់...ដែលធ្វើឱ្យការតាមដាន និងវាយតម្លៃមិនបានត្រឹមត្រូវឡើយ។

## ៤. សំណូមពរ

៥២. ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមខាងលើ និងដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ក្នុងការអភិវឌ្ឍកៅស៊ូ ឱ្យទទួលបានជោគជ័យតាមការគ្រោងទុកក្នុងទិសដៅខាងមុខក៏ដូចជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកៅស៊ូនៅកម្ពុជា២០១១-២០២០ នោះ អគ្គនាយកដ្ឋានកៅស៊ូ សូមសំណូមពរមួយចំនួនជូនថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មេត្តាពិនិត្យលទ្ធភាពដ៏ខ្ពង់ខ្ពស់ ជួយដោះស្រាយដូចមានខាងក្រោម៖

- ជួយអន្តរាគមន៍ទៅក្រុមហ៊ុនវិនិយោគលើដីសម្បទានសេដ្ឋកិច្ចដាំដុះកៅស៊ូ ទាំងអស់ សហការជាមួយនាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានកៅស៊ូដើម្បីផ្តល់ឲ្យបានអំពីស្ថិតិកៅស៊ូ និងសម្រាប់រៀបចំគោលនយោបាយកៅស៊ូថ្នាក់ជាតិដែលរាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ខ្ពស់។
- ជួយអន្តរាគមន៍ទៅក្រសួងនិងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ផ្តល់ការសហការល្អជាមួយអគ្គនាយកដ្ឋានកៅស៊ូ។
- ជួយអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម ដើម្បីអនុវត្តតាមស្មារតីអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ។
- ជួយអន្តរាគមន៍ និងផ្តល់ទីតាំងផ្ទៃដី សម្រាប់ធ្វើអនុស្ថានីយ៍ពិសោធន៍នៅតាមតំបន់មានដំណាំកៅស៊ូ។
- ជួយផ្តល់ប្រេងឥន្ធនៈ ថវិកា ពិសេសមធ្យោបាយធ្វើដំណើរ(បច្ចុប្បន្នអគ្គនាយកដ្ឋានកៅស៊ូ មានតែរថយន្ត Pick Up ចាស់ៗ ចំនួន២គ្រឿងប៉ុណ្ណោះ) ឱ្យបានសមរម្យនិងទាន់ពេលវេលា។

## ៥. សន្និដ្ឋាន

៥៣. លទ្ធផលការងារដែលអគ្គនាយកដ្ឋានកៅស៊ូសម្រេចបាននៅក្នុងឆ្នាំ២០១៣ កន្លងមកនេះបានបង្ហាញឲ្យឃើញថា ទោះបីជាមានការលំបាកនិងជួបបញ្ហាប្រឈមជាច្រើនយ៉ាងណាក៏ដោយ ឈរលើស្មារតីសាមគ្គីភាពឯកភាពផ្ទៃក្នុងរវាងជួរថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃអគ្គនាយកដ្ឋានកៅស៊ូបានខិតខំអស់ពីកម្លាំងកាយចិត្តដើម្បីអនុវត្តឲ្យបានតាមទិសដៅ និងផែនការដែលបានកំណត់។ ម្យ៉ាងទៀតសមិទ្ធផលទាំងនេះមួយចំណែកធំគឺ អាស្រ័យដោយសារការគាំទ្រ ជំរុញដាស់តឿននិងណែនាំពីថ្នាក់ដឹកនាំក្រសួងកសិកម្ម ជាពិសេស ពីសំណាក់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជានិច្ចកាលតែងបានផ្តល់នូវអនុសាសន៍ល្អៗដល់មន្ត្រីរាជការ និងមានការគាំទ្រទាំងស្មារតី និងថវិកា ដើម្បី

អនុវត្តការងារបានប្រកបដោយផ្លែផ្កានិងមានប្រសិទ្ធភាពខ្ពស់។

## ៦. ទិសដៅការងារឆ្នាំ២០១៤

៩៤. ដើម្បីសម្រេចបាននូវភារកិច្ចនានាក្នុងឆ្នាំខាងមុខ និងសមស្របតាមយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍដំណាំកៅស៊ូនៅកម្ពុជាឆ្នាំ២០១១-២០២០ និងដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ គឺការលើកស្ទួយវិស័យកសិកម្មដើម្បីលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម។ អគ្គនាយកដ្ឋានកៅស៊ូមានទិសដៅអនុវត្តការងារបន្តដូចខាងក្រោម៖

- បន្តអនុវត្តតួនាទី និងភារកិច្ចដើម្បីឱ្យដំណើរការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងការិយាល័យក្រោមឱវាទ ឱ្យស្របតាមខ្លឹមសារនៃអនុក្រឹត្យលេខ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងបន្តអនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រគល់ឱ្យ។
- ពិនិត្យឡើងវិញអំពីការកំណត់អនុកម្មវិធី និងសូចនាករដើម្បីឱ្យសមស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ និងផែនការយុទ្ធសាស្ត្រវិស័យកសិកម្ម ឆ្នាំ២០១៤-២០១៨។
- ពិនិត្យតាមដានការអនុវត្តផែនការកម្មវិធីវិនិយោគ លើដីសម្បទានសេដ្ឋកិច្ចសង្គមកិច្ច និងវាយតម្លៃលទ្ធផលដែលសម្រេចបាន
- បង្កើនកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានខេត្ត ស្រុក ដើម្បីជួយទប់ស្កាត់សកម្មភាពបើកស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ ដែលគ្មានលិខិតអនុញ្ញាតនិងជាមួយសមត្ថកិច្ចនៅតាមច្រកព្រំដែន ជួយទប់ស្កាត់ការនាំចេញជ័រនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេសដោយខុសច្បាប់
- កែសម្រួល និងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍដំណាំកៅស៊ូនៅកម្ពុជាឆ្នាំ២០១១-២០២០
- ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារ និងអង្គការកៅស៊ូអន្តរជាតិនានាលើកិច្ចសហប្រតិបត្តិការ ក្នុងក្របខ័ណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិជ្ជាវិទ្យាសាស្ត្រ
- ខិតខំកៀរគរកដៃគូសហប្រតិបត្តិការក្នុងការគាំទ្រថវិកានិងបច្ចេកទេសដើម្បីជួយទ្រទ្រង់ដល់ការអភិវឌ្ឍកៅស៊ូគ្រួសារ
- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវ និងកសាងលិខិតគតិយុត្តិពាក់ព័ន្ធ និង



រៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូបញ្ចប់

- បន្តការបើកវគ្គផ្សព្វផ្សាយនិងបណ្តុះបណ្តាលស្តីពីការដាំដុះថែទាំកូនកៅស៊ូ ការប្រើប្រាស់ថ្នាំសម្លាប់ស្មៅ ការគ្រប់គ្រងសមាសភាពចង្រៃ និងជំងឺកៅស៊ូ និងការប្រមូលផលដល់កសិករបន្ថែមទៀត
- អនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ (CSR) សម្រាប់នាំចេញ
- បន្តការប្រមូលយកគម្រូស្លឹកកៅស៊ូ នៅតាមបណ្តាច្បារពូជតាមបណ្តាខេត្ត ដើម្បីធ្វើការវិភាគ DNAតាមផែនការ និងដាំជួសក្លូន ដែលបានកំណត់ក្នុងគម្រោងធម្មនិយាមកម្មច្បារពូជ។
- ទំនាក់ទំនងកិច្ចសហប្រតិបត្តិការ ជាមួយសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ ជាពិសេសពិនិត្យគោលនយោបាយ បេសកកម្ម និងសកម្មភាពរបស់ក្រុមប្រឹក្សាកៅស៊ូត្រីភាគីអន្តរជាតិដែលស្នើសុំអញ្ជើញកម្ពុជា ឡាវ និងវៀតណាម ឲ្យចូលជាសមាជិកក្នុងក្រុមប្រឹក្សានេះ៕

